# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ក្ដី ជ្រើសរើសតំណាងរាស្ត្រក្ដីនៅប្រទេសកម្ពុជា ត្រូវមានលក្ខណៈសេរី និងយុត្តិធម៌

website : www.hoksavann.org

ថ្ងៃទី១១ មីនា ២០០៧



តាមកិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជាឆ្នាំ១៩៩១ នៅទីក្រុងប៉ារីសប្រទេសបារាំង ក្រោមកិច្ចចាត់ចែងនៃអង្គការសហប្រជាជាតិ តម្រូវឲ្យប្រទេសកម្ពុជាកាន់របបប្រជាធិបតេយ្យពហុបក្ស ។ ដូច្នេះក្នុងន័យនេះ ប្រជាពលរដ្ឋខ្មែរជាម្ចាស់អំណាច ត្រូវជ្រើសរើអ្នកកាន់ការរដ្ឋ តាមរយៈការបោះឆ្នោត ។ អស់រយៈកាលបីអាណត្តិហើយ ក្នុង៥ឆ្នាំម្ដង ចាប់ពីឆ្នាំ១៩៩៣មក ក្នុងការជ្រើសរើសតំណាងរាស្ត្រ ប្រ-ទេសកម្ពុជាត្រូវមតិជាតិនិងមតិអន្តរជាតិចោទថា ការបោះឆ្នោតនោះពុំមានសេរីនិងយុត្តិធម៌ឡើយ ជាពិសេសការបោះឆ្នោតពីរលើកចុងក្រោយ ដែលពុំចាត់ចែងដោយអង្គការសហប្រជាជាតិ ព្រោះរាល់តែពេលបោះឆ្នោត តែងតែមានការចោទប្រកាន់គ្នាទៅវិញទៅមក រវាងគណ-បក្សអ្នកកាន់អំណាច គឺកណាបក្សប្រជាជនកម្ពុជា និងគណាបក្សប្រឆាំង រហូតដល់មានអំពើហឹង្សាលួចសម្លាប់គ្នាទៀតផង ។

នៅឆ្នាំ២០០៧នេះ ប្រទេសកម្ពុជាត្រូវបោះឆ្នោតត្រូវបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ និងឆ្នាំ២០០៨ បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ តើការបោះឆ្នោតឲ្យមានលក្ខណៈសេរីនិងយុត្តិធម៌មានសភាពបែបណា ។ ដើម្បីឲ្យការបោះឆ្នោតប្រកបដោយសេរីនិងយុត្តិធម៌ ជាការឆ្លុះបញ្ចាំងនូវឆន្ទៈរបស់ប្រជាពលរដ្ឋពិតប្រាកដ, គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំអនុវត្តការងារឲ្យមានភាពត្រឹមត្រូវ តាំងពីខាងដើមរហូតដល់ទីបំផុត ។ គឺមានភាពត្រឹមត្រូវតាំងពីការចុះឈ្មោះ ការឃោស

នា ពេលបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល ។ ការចុះឈ្មោះ គឺ
ពុំបង្កការលំបាកក្នុងការចុះឈ្មោះ  ឬឲ្យចុះឈ្មោះបានងាយចំពោះតែជនណាដែល
សំគាល់ថា នឹងបោះឆ្នោតឲ្យគណបក្សរបស់ខ្លួន នេះជាការលំអៀងរបស់អ្នករៀបចំ
ការបោះឆ្នោត ។ ពេលវេលាកំពុងរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-ស
ង្កាត់  តាមពត៌មានជាបន្តបន្ទាប់គ្នាពីប្រទេសកម្ពុជាថា  ជនខ្លះមិនទាន់បានអត្តសញ្ញា
ណប័ណ្ណ  ជនខ្លះមិនទាន់បានប័ណ្ណពត៌មានបោះឆ្នោត  ជនខ្លះខុសឈ្មោះជាដើម  ។
មួយទៀតត្រូវពិនិត្យមើលកុំឲ្យមានការចុះឈ្មោះបន្លំ ដូចមានពាក្យចោទពីគណបក្ស
ប្រឆាំងថា មានជនជាតិវៀតណាមជាច្រើនបន្លំចុះឈ្មោះ ។ ការឃោសនា ត្រូវប្រព័ន្ធ
ឃោសនារបស់រដ្ឋវិទ្យុនិងទូរទស្សន៍  ត្រូវបែងចែកឲ្យគ្រប់គណបក្សទាំងអស់មាន
ពេលវេលាស្មើគ្នាក្នុងការឃោសនា ។ មានពាក្យចោទថា វិទ្យុនិងទូរទស្សន៍របស់រដ្ឋ
បានត្រូវគណបក្សកាន់អំណាចយកមកប្រើជានិច្ច  តាំងពីមុនការរៀបចំការបោះឆ្នោ
តទៅទៀត ។ ពេលបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល ក៏ត្រូវ
ធ្វើឲ្យត្រឹមត្រូវ មិនបោះឆ្នោតបន្លំ កុំរាប់សន្លឹកឆ្នោតបន្លំ មិនប្រកាសលទ្ធផលបន្លំ មិ
នលួចបន្លំហឹបឆ្នោតជាដើម ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត  ត្រូវប្រកាន់គោលជំហរអព្យាក្រឹត្យនិ
ងឯករាជ្យ  មិនស្ថិតនៅក្រោមអំណាចនៃរាជរដ្ឋាភិបាល  ហើយជៀសវាងការបោះ
ឆ្នោតដោយការស្លូកប៉ាន់ ដោយការលួងលោមផ្លូវចិត្ត ដោយការគំរាមកំហែង និង
ដោយការបន្លំសន្លឹកឆ្នោតជាដើម ទើបចាត់ថាបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ,

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នៅឆ្នាំ២០០៧ និងការបោះឆ្នោ
តក្នុងអាណត្តិទី៤ឆ្នាំ២០០៨ គេអនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោត ។ សូមរំលឹកឡើង
វិញថា ក្នុងអាណត្តិទី១និងទី២ ក៏គេអនុញ្ញាតឲ្យព្រះសង្ឃបោះឆ្នោតជ្រើសរើសតំ-
ណាងរាស្ត្រដែរ  ប៉ុន្តែគេមិនអនុញ្ញាតវិញក្នុងអាណត្តិទី៣ឆ្នាំ២០០៣ដល់ឆ្នាំ២០០៨
ឥឡូវក្នុងអាណត្តិទី៤ គេអនុញ្ញាតឡើងវិញ ។ ម្តងអនុញ្ញាត ម្តងមិនអនុញ្ញាតវិញ
ដូចនេះ ជាសេចក្តីសំរេចរបស់ប្រមុខដឹកនាំនៃរាជរដ្ឋាភិបាល ដែលសមាជិកគណៈ
រដ្ឋមន្ត្រីភាគច្រើនចេញមកពីគណបក្សប្រជាជនកម្ពុជា ។ ម្តងឲ្យបោះម្តងមិនឲ្យបោះ
នេះ ជាសេចក្តីសំរេចឃោលទៅតាមការមានប្រយោជន៍ ឬមិនមានប្រយោជន៍ដល់
បក្សប្រជាជន  គឺព្រះសង្ឃបោះឲ្យបក្សប្រជាជនចាំតែអនុវត្តតាមបក្សប្រជាជនប៉ុ-
ណ្ណោះ ។ ដោយព្រះពុទ្ធសាសនាខ្មែរសព្វថ្ងៃនេះ ស្ថិតនៅក្រោមអំណាចអូសទាញ
របស់អ្នកនយោបាយនេះហើយ  បានជាយើងជំទាស់នឹងការឲ្យព្រះសង្ឃបោះឆ្នោត
នេះ ដោយសង្កេតឃើញកន្លងមក ព្រះសង្ឃអង្គណាមិនចូលបក្សប្រជាជន ត្រូវគេ
ធ្វើបាប ហើយនៅឆ្នាំ១៩៩៨ គេបាញ់ធ្វើគតព្រះសង្ឃ ក្នុងឱកាសបាតុកម្មរាប់សន្លឹក
ឆ្នោតឡើងវិញ ។

មួយទៀតការបោះឆ្នោតនេះ  ធ្វើឲ្យព្រះសង្ឃនិងព្រះសង្ឃបែកបាក់សាមគ្គីគ្នា

ទៀត ដោយសារការប្រកាន់គណបក្សរៀងខ្លួន ដែលធ្វើឲ្យតម្លៃព្រះសង្ឃ ដែលគេតែងគោរពត្រូវធ្លាក់ចុះ ។ ព្រះសង្ឃគួរស្ថិតនៅជាអព្យាក្រឹត្យនិងឯករាជ្យ ទុកជាគ្រូរំលឹកតាមផ្លូវព្រះធម៌គ្រប់គណបក្សទាំងអស់ យកគណបក្សទាំងអស់ជាមិត្ត ប្រសើរជាងទៅបោះឆ្នោត ។ តាមដំណឹងពីប្រទេសកម្ពុជាមកថា ព្រះសង្ឃវត្តលង្កា វត្តបុទុម វត្តឧណ្ណាលោម ត្រូវគេបង្ខំឲ្យចូលគណបក្សប្រជាជន ដូច្នេះឃើញថាអ្នកនយោបាយលូកដៃចូលមកក្នុងផ្ទៃសង្ឃបែបនេះ ដោយសារព្រះសង្ឃប្រើសិទ្ធិពេះឆ្នោតនេះ ។ ចំណែកអាចារ្យហែម-ចៀវនិងព្រះសង្ឃខ្មែរកម្ពុជាក្រោម ជាករណីពិសេសដោយឡែក ដែលតស៊ូប្រឆាំងនឹងបរទេសឈ្លានពាន ។ ពេលនេះយើងចង់រក្សាតម្លៃព្រះពុទ្ធសាសនា ដែលជាស្ថាប័នបរិសុទ្ធរបស់ជាតិខ្មែរ កុំឲ្យសៅហ្មងដោយសាររឿងនយោបាយ ហើយចាំមើលអនាគតទៀត គឺនៅពេលដែលប្រទេសកម្ពុជា មានការគោរពសិទ្ធិមនុស្ស និងមានប្រជាធិបតេយ្យចាស់ទុំ ចាំយើងយកបញ្ហាព្រះសង្ឃបោះឆ្នោតនេះមកពិចារណាម្តងទៀត ។

ចំពោះគណបក្សនានានិងអង្គការក្រៅរដ្ឋាភិបាល ដែលចង់ឲ្យព្រះសង្ឃបោះឆ្នោតនោះ គឺគេគិតត្រឹមតែថា ព្រះសង្ឃគឺជាពលរដ្ឋខ្មែរដែរ ប៉ុន្តែគេមិនបានគិតឲ្យជ្រៅទៅទៀតថា ព្រះសង្ឃក៏ជាពលរដ្ឋខ្មែរ ប៉ុន្តែជាពលរដ្ឋពិសេស គឺពិសេសដោយគុណធម៌ មានមុខងារផ្សេងពីគ្រហស្ថ ផ្នែកខ្លះអាចចូលរួមជាមួយគ្រហស្ថបាន ចំណែកផ្នែកខ្លះបើចូលរួមទៅ អាចឲ្យព្រះពុទ្ធសាសនាដែលជាស្ថាប័នកំពូលរបស់ជាតិនេះ មានគុណវិបត្តិ សូមពិចារណាឲ្យមែនទែន ហើយពិចារណាមើលពេលវេលាគួរចូលរួមឬមិនគួរផង ។

ចំពោះប្រជាពលរដ្ឋខ្មែរជាគ្រហស្ថវិញ ការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ដើម្បីបង្កើតរដ្ឋាភិបាលដឹកនាំជាតិ គឺជាកាតព្វកិច្ចដែលត្រូវធ្វើ ។ ប៉ុន្តែត្រូវប្រើសិទ្ធិនេះឲ្យបានត្រឹមត្រូវ គឺត្រូវជ្រើសរើសអ្នកដឹកនាំដែលមាមសមត្ថភាព មានគុណធម៌ អាចបំរើផលប្រយោជន៍ខ្លួននិងផលប្រយោជន៍ជាតិបាន ។ បើប្រើសិទ្ធិនេះខុសដោយបោះឆ្នោតឲ្យជនណាឲ្យបក្សណាដែលគ្មានគុណសម្បត្តិជាអ្នកដឹកនាំ នោះទុកជាអាវុធសំរាប់ខ្លួនសម្លាប់ជាតិវិញ ។ បញ្ហាប្រទេសកម្ពុជាសព្វថ្ងៃនេះ គឺត្រូវជ្រើសរើសគណបក្សណា ដែលអាចការពារបូរណាភាពទឹកដី ត្រួតពិនិត្យមើលជនអន្តោប្រវេសន៍ខុសច្បាប់ មិនរណបបរទេស កំចាត់ភាពក្រីក្រ កំចាត់អំពើពុករលួយ កំចាត់អ្នកមានអំណាចរឹបអូសដីធ្លីប្រជាពលរដ្ឋ កំចាត់អ្នកកាប់បំផ្លាញព្រៃឈើ រៀបចំតុលាការឲ្យមានយុត្តិធម៌ជាដើម ត្រូវបោះឆ្នោតឲ្យគណបក្សនោះ ។ ដើម្បីសំរេចគោលបំណងនេះបាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបោះឆ្នោតឲ្យបានត្រឹមត្រូវ ដោយពុំលំអៀងទៅលើគណបក្សណាមួយ ។ ចំណែកប្រជាពលរដ្ឋខ្លួនឯង ក៏សំរេចចិត្តឲ្យបានត្រឹមត្រូវដូចពោលខាងលើ ដោយប្រើបញ្ញាពិចារណាឲ្យបានល្អិតល្អន់ មុននឹងគូសសន្លឹកឆ្នោតដាក់ក្នុងហឹប ។ ពេលបោះឆ្នោតម្តងៗ គ្រប់

គណបក្សទាំងអស់ តែងតែរកវិធីទាក់ទាញទឹកចិត្តប្រជាពលរដ្ឋឲ្យបោះឆ្នោតឲ្យខ្លួនមានលួងលោមផ្លូវចិត្ត ធានាជួយអ្វីមួយ ចែកអំណោយ និងការគំរាមកំហែងជាដើម ប៉ុន្តែប្រជាពលរដ្ឋមុននឹងប្រគល់សន្លឹកឆ្នោតឲ្យគណបក្សណា ត្រូវពិចារណាឲ្យបានម៉ត់ចត់ ដើម្បីកុំឲ្យស្ដាយក្រោយ ដោយសារតែការសំរេចចិត្តខុស ។៚